**BRIEFING NOTES**

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៥

អ្នកនាំពាក្យរបស់ឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស៖ លោក Rupert Colville
ទីតាំង៖ ទីក្រុងហ្សឺណែវ

កម្មវត្ថុ៖ (១) ប្រទេសប៊ូរុនឌី
(២) ប្រទេសយេមែន
(៣) ប្រទេសកម្ពុជា
(៤) ប្រទេសកុងហ្គោ

**(៣) ប្រទេសកម្ពុជា**

យើងកត់សម្គាល់ថាសេចក្តីសម្រេចរបស់រដ្ឋាភិបាលកម្ពុជាមិនបន្តបញ្ជូនខ្លួនក្រុមម៉ុងតាញ៉ា ១៣ នាក់ ដែលមានឋឋានៈជាជនភៀសខ្លួន ត្រឡប់ទៅប្រទេសវៀតណាមវិញតាមការគ្រោងរបស់ខ្លួនឡើយ នៅខែនេះ។ រដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ការទាមទារសិទ្ធិជាជនភៀសខ្លួនរបស់ពួកគេហើយការវិលត្រឡប់របស់ពួកគេទៅកាន់ប្រទេសវៀតណាមវិញ អាចចាត់ថាជា*ការបញ្ជូនត្រឡប់ទៅវិញ*ហើយហានិភ័យនានាដែលនឹងធ្វើឲ្យជនភៀសខ្លួនទទួលរងនូវការរំលោភសិទ្ធិមនុស្ស រាប់ទាំងការចាប់ខ្លួនដោយបំពាននិងការធ្វើទារុណកម្ម។ ក្នុងនាមជារដ្ឋភាគីនៃអនុសញ្ញាជនភៀសខ្លួន និងអនុសញ្ញាប្រឆាំងទារុណកម្មនិងក្នុងនាមជាប្រទេសមួយដែលប្រកាន់ខ្ជាប់នូវគុណតម្លៃជាសកលដែលមានចែងក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស* ប្រទេសកម្ពុជាត្រូវមានកាតព្វកិច្ចមិនបញ្ជូនជនភៀសខ្លួនត្រឡប់ទៅប្រទេសដែលពួកគេអាចនឹងទទួលរងនូវការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ។

រដ្ឋាភិបាលបានប្រកាសកាលពីថ្ងៃអង្គារថាខ្លួននឹងពន្យារពេលកំណត់ក្នុងការបញ្ជូនជនភៀសខ្លួនទាំងនោះត្រឡប់ទៅវិញ រហូតដល់ថ្ងៃទី១០ខែមករាឆ្នាំ២០១៦។យើងសូមអំពាវនាវដល់រដ្ឋាភិបាលក្នុងការធានាថាសិទ្ធិរបស់បុគ្គលទាំង១៣ នាក់នេះ នឹងត្រូវបានការពារយ៉ាងពេញលេញ រាប់ទាំងការការពារពីរាល់ហានីភ័យទាំងអស់នៃ*ការបញ្ជូនត្រឡប់ទៅវិញ*។

យើងសូមជម្រុញឲ្យកម្ពុជាអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការចុះឈ្មោះនិងពិនិត្យពិចារណាលើរាល់ការសុំសិទ្ធិជ្រកកោនដែលនៅសល់ទាំងអស់របស់ក្រុមម៉ុងតាញ៉ាដែលបានចាកចេញពីប្រទេសវៀតណាមដោយបានអះអាងថាត្រូវបានគេធ្វើទុក្ខបុកម្នេញខាងសាសនា នយោបាយ និងការធ្វើទុក្ខបុកម្នេញផ្សេងទៀតមានក្រុម

ម៉ុងតាញ៉ាច្រើនជាង ២០០នាក់បានមកដល់ប្រទេសកម្ពុជាកាលពីឆ្នាំមុន។នៅសប្តាហ៍នេះរដ្ឋាភិបាលបានពន្យារពេលកំណត់រហូតដល់ថ្ងៃទី៦ខែកុម្ភៈដើម្បីឲ្យអ្នកទាំងអស់នោះវិលត្រឡប់ទៅប្រទេសវៀតណាមវិញ ឬត្រូវបញ្ជូនដោយបង្ខំត្រឡប់ទៅវិញ។ យើងជឿថាការពន្យាពេលនេះនឹងផ្តល់ពេលវេលាដល់រដ្ឋាភិបាលឲ្យពិនិត្យពិចារណាឡើងវិញលើពាក្យសុំសិទ្ធិជ្រកកោនរបស់ពួកគេ ស្របតាមបទដ្ឋានអន្តរជាតិ ហើយថាទោះជាក្នុងករណីណាក៏ដោយមិនត្រូវបញ្ជូនត្រឡប់ទៅវិញនូវជនស្វែងរកសិទ្ធិជ្រកកោន ដោយមិនបានធ្វើការពិនិត្យពិចារណាលើពាក្យសុំរបស់បុគ្គលម្នាក់ៗដែលទាមទារសិទ្ធិរបស់ខ្លួននោះឡើយ។ ទាំងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) ទាំងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) បានសរសេរលិខិតទៅរដ្ឋាភិបាលកម្ពុជាកាលពីឆ្នាំមុន ដោយជម្រុញថា បុគ្គលទាំងអស់នោះត្រូវបានអនុញ្ញាតឲ្យបន្តការស្នើសុំសិទ្ធិជ្រកកោនរបស់ខ្លួនតទៅទៀត។

**ចប់**

*សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលោក Rupert Colville (+៤១២២៩១៧៩៧៦៧/ rcolville@ohchr.org) ឬ Cécile Pouilly (+៤១ ២២ ៩១៧ ៩៣១០/ cpouilly@ohchr.org).*